ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៨៧
ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០២៣
ជំនុំជម្រះ:
លេខ: ៥៥២
ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០២៣
សាលក្រម
លេខ: ០១ "ក"
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជំនុំជម្រះជាអសាធារណ: នៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

## សមាសភាពជំនុំជម្រះ

លោកជំទាវ [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

## ដើម្បីជំនុំជម្រះ

**រឿងក្តីព្រហ្មទណ្ឌលេខ: ៥៨៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ:**

១-ឈ្មោះ: [redacted] វង្ហា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងកំណើត ភូមិ [redacted] ខេត្តព្រៃវែង និងមានទីលំនៅមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តតាកែវ កាន់សាសនាព្រះពុទ្ធ ឪពុកឈ្មោះ: ចន (ស្លាប់) ម្តាយឈ្មោះ: [redacted] ជឿក (រស់) មានប្រពន្ធឈ្មោះ: [redacted] ឌិប (រស់) មានកូនចំនួន ០១នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន ។ **(ឃុំខ្លួនថ្ងៃទី០៩.០៦.២០២៣)**

២-ឈ្មោះ: [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងមានទីលំនៅមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ: [redacted] ចក់ (រស់) ម្តាយឈ្មោះ: [redacted] ឌី (រស់) នៅលីវ ជាអនីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន ។ **(ឃុំខ្លួនថ្ងៃទី០៩.០៦.២០២៣)**

ជាប់ចោទពីបទ: **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គញ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ: [redacted] ចាន់ ។

-**បានឃើញ:** ដីកាសន្និដ្ឋានស្ថាពរលេខ: ៤៦២ ដ.ស.ព/២៣ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។



Scanned with CamScanner

-**បានឃើញ**: ដីកាដំណោះស្រាយលេខ: ៨១៣/២០២៣ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ: **៥៥២ ដចត/២៣** ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: ឯកសារផ្សេងៗ ក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

## <u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១៣ និង ៣០ នាទី កម្លាំងអធិការដ្ឋាននគរបាលស្រុកទ្រាំង បានចុះបង្ក្រាបករណី រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅចំណុចភូមិអង្គញ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ បានធ្វើការឃាត់ខ្លួនជនជាប់ចោទចំនួន ០២នាក់ ១.ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ២៨ឆ្នាំ ២.ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ ។ ពេលឃាត់ខ្លួនសមត្ថកិច្ចដកហូតបានគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ICE បានចំនួន ០១កញ្ចប់តូច មានទម្ងន់ ០,១៨ក្រាម, ទូរស័ព្ទម៉ាក OPPO ចំនួន ០១គ្រឿង ពណ៌ក្រហម, ម៉ូតូចំនួន ០១គ្រឿងម៉ាក គុបជ្រុង ពណ៌ទឹកប៊ិច ពាក់ស្លាកលេខ ភ្នំពេញ 1AC-1346 ។ បន្ទាប់មកសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ២៨ឆ្នាំ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ មានលក្ខណៈប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខ្លួននិងឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ រស់នៅភូមិព្រៃមាស ឃុំអង្គខ្នុរ ស្រុកទ្រាំង ខេត្តតាកែវ បានជិះម៉ូតូមកដល់ផ្ទះពូរបស់ឈ្មោះ [redacted] ចាន់ ហើយបានសួរខ្លួនថាមានលុយអត់បន្ទាប់មកខ្លួន និងឈ្មោះ [redacted] ចាន់ ក៏បានជិះម៉ូតូឌុបទៅទិញថ្នាំញៀននៅម្តុំភ្នំសន្លងខាងកើតផ្លូវ ពីបុរសម្នាក់មិនស្គាល់ឈ្មោះចំនួន ០១កញ្ចប់ តូចក្នុងតម្លៃ២ម៉ឺនរៀល ។ ពេលទិញបានថ្នាំញៀនហើយខ្លួនក៏បានជិះម៉ូតូត្រឡប់មកផ្ទះវិញពេលមកដល់វត្តអង្គញ ក៏មានសមត្ថកិច្ចចុះមកឃាត់ខ្លួន និងឆែកឆេរហើយបានដកហូតថ្នាំញៀនចំនួន ០១កញ្ចប់តូច និងម៉ូតូមួយគ្រឿងរបស់ឈ្មោះ [redacted] ចាន់ ។ ខ្លួនពុំធ្លាប់ស្គាល់ឈ្មោះ អ្នកលក់ថ្នាំញៀននោះទេទើបតែទិញម្តងនេះតែប៉ុណ្ណោះ ហើយក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ សម្ភារៈដែលដកហូតមានថ្នាំញៀនចំនួន ០១កញ្ចប់តូច និងម៉ូតូចំនួន ០១គ្រឿងម៉ាកគុបជ្រុង ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ មានលក្ខណៈប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខ្លួននិងឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ២៨ឆ្នាំ បានជិះម៉ូតូឌុបគ្នាទៅទិញថ្នាំ ពីបុរសម្នាក់មិនស្គាល់ឈ្មោះចំនួន ០១កញ្ចប់តូចក្នុងតម្លៃ ២ម៉ឺនរៀល ដោយចូលលុយគ្នាក្នុងម្នាក់ចំនួន ១ម៉ឺនរៀល ។ ពេលបានថ្នាំញៀនហើយខ្លួនក៏បានជិះម៉ូតូត្រឡប់មកវិញពេលមកដល់ចំណុចវត្តអង្គញ ក៏មានសមត្ថកិច្ចចុះមកឃាត់ខ្លួន និងឆែកឆេរដកហូតថ្នាំញៀនចំនួន ០១កញ្ចប់តូច និងម៉ូតូចំនួន ០១គ្រឿងម៉ាកគុបជ្រុង ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា មានវត្តមាន ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ មានវត្តមាន ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ មានវត្តមាន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ភេទប្រុស អាយុ២៨ឆ្នាំ បានឆ្លើយថា នៅថ្ងៃកើតហេតុពួកខ្លួនបបួលគ្នាចូលលុយដើម្បីជិះម៉ូតូទៅទិញថ្នាំញៀនជាមួយគ្នា ។ ខ្លួនទៅទិញថ្នាំញៀនចំនួន០១ កញ្ចប់ តម្លៃពីរម៉ឺនរៀល ។ ពីមុនមកខ្លួនចេះប្រើប្រាស់គ្រឿងញៀនហើយក៏បានដឹងថាឈ្មោះ [redacted] ចាន់ ក៏ចេះប្រើប្រាស់ដែរ ។ សមត្ថកិច្ចឃាត់ពួកខ្លួនគឺ នៅពេលពួកខ្លួនត្រឡប់មកពីទិញថ្នាំញៀនវិញ ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ បានឆ្លើយថា នៅថ្ងៃកើតហេតុពួកខ្លួនបានចូលលុយគ្នា ទៅទិញថ្នាំញៀនយកមកប្រើប្រាស់ទាំងពីរនាក់ដោយខ្លួនជាអ្នកបើកម៉ូតូ ។ ខ្លួនស្គាល់ឈ្មោះ [redacted] វដ្ឋា ដែលជាអ្នកភូមិជាមួយគ្នាចម្ងាយពីផ្ទះខ្លួន ទៅផ្ទះរបស់ឈ្មោះ [redacted] វដ្ឋា ប្រហែលមួយគីឡូដី ។ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនពីពួកខ្លួនចំនួន ០១ កញ្ចប់ ។ ម៉ូតូដែលពួកខ្លួនឌុបគ្នាជាម៉ូតូរបស់តាខ្លួន ។ ខ្លួនប្រើប្រាស់គ្រឿងញៀនមួយខែម្តង ។ ពេលទៅទិញថ្នាំញៀនខ្លួនទៅជាមួយឈ្មោះ [redacted] វដ្ឋា ដោយខ្លួនជាអ្នកបើកម៉ូតូ ។ ខ្លួនមិនស្គាល់ឈ្មោះអ្នកលក់ថ្នាំញៀននោះទេ តែស្គាល់ផ្ទះរបស់អ្នកលក់ និងមិនស្គាល់លេខទូរស័ព្ទអ្នកលក់ទេ ។ ពីមុនមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] វដ្ឋា ដែរ ។

-អំណានកំណត់ហេតុធ្វើតេស្តរកសារធាតុញៀនលេខ: ០៩/០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ លើឈ្មោះ [redacted] វដ្ឋា ភេទប្រុស អាយុ២៨ឆ្នាំ បានបញ្ជាក់ថា **វិជ្ជមាន** ។

-អំណានកំណត់ហេតុធ្វើតេស្តរកសារធាតុញៀនលេខ: ០៩/០៩ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ លើឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ បានបញ្ជាក់ថា **វិជ្ជមាន** ។

-អំណានកំណត់ហេតុចាប់យកវត្ថុតាង៖ ម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់តូច មានទម្ងន់ ០,១៨ ក្រាម, ទូរស័ព្ទម៉ាក OPPO ចំនួន ០១គ្រឿង ពណ៌ក្រហម, ម៉ូតូចំនួន ០១គ្រឿងម៉ាក គុបជ្រុង ពណ៌ទឹកប៊ិច ពាក់ស្លាកលេខភ្នំពេញ 1AC-1346 ។ (កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣) ។

-អំណានកំណត់ហេតុទទួលវត្ថុតាង របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តតាកែវ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានពិនិត្យមើលឯកសារនានានៅក្នុងសំណុំរឿង ក្រោយពីបានពិភាក្សាដេញដោល និងក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ រួចមកឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរ ប្រាកដមែន ។ ដូចនេះតំណាងអយ្យការស្នើសុំឱ្យតុលាការផ្តន្ទាទោសទៅលើជនជាប់ចោទតាមច្បាប់ ដោយរក្សាទុកបទចោទប្រកាន់ទុកនៅដដែល ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ បានសន្និដ្ឋានថា ក្រោយពីបានពិភាក្សាដេញដោលជាអសាធារណៈ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់កូនក្តីខ្លួន និងក្រោយពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង គឺពិតជាមានអង្គហេតុដូចការចោទប្រកាន់ប្រាកដមែន ប៉ុន្តែនៅថ្ងៃកើតហេតុកូនក្តីរបស់ខ្លួនពុំបានប្រព្រឹត្តអំពើ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀននោះទេ គឺគ្រាន់តែកូនក្តីរបស់ខ្លួនចូលលុយគ្នាទៅទិញថ្នាំញៀនដើម្បីយកមកប្រើប្រាស់តែប៉ុណ្ណោះ ម្យ៉ាងទៀតកូនក្តីរបស់ខ្លួនជាអនីតិជនពុំទាន់ចេះពិចារណាដឹងខុសត្រូវនៅឡើយ ដូច្នេះខ្លួនស្នើសុំឱ្យ



Scanned with CamScanner

តុលាការ ប្តូរបទចោទប្រកាន់លើកូនក្តីរបស់ខ្លួនពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន មកបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន វិញ ។

-ជនជាប់ចោទបានសំណូមពរចុងក្រោយថា ខ្លួនសូមសំណូមពរដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង ព្រោះពួកខ្លួនបានដឹងពីកំហុសហើយ ។

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ

## <u>សាលាដំបូងខេត្តតាកែវ</u>

## <u>យល់ឃើញថា</u>

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា, តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ និងការពិនិត្យភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងតុលាការរកឃើញថា ពិតជាមាននូវអំពើៈ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គុញ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ភេទប្រុស អាយុ២៤ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ ប្រាកដមែន ។ អំពើនេះជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រ ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-គ្មានភស្តុតាងណាមួយបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ភេទប្រុស អាយុ២៤ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ ជាជនវិកលចរិត ឬ វិបល្លាសស្មារតីឡើយ ផ្ទុយទៅវិញជនជាប់ចោទជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ភេទប្រុស អាយុ២៤ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ ពីបទៈ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គុញ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃ០៨ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ការប្រព្រឹត្តរបស់ជនជាប់ចោទក៏ដោយសារតែភាពអវិជ្ជា ភាពក្រីក្រ ហើយជនជាប់ចោទក៏បានសហការជាមួយតុលាការ ដោយបានឆ្លើយសារភាពឥតលាក់លៀមនូវអំពើប្រព្រឹត្តរបស់ខ្លួន និងបានទទួលស្គាល់នូវកំហុសរបស់ខ្លួន ។ ស្ថានភាពទាំងអស់នេះគប្បីតុលាការពិចារណាក្នុងការដាក់ទណ្ឌកម្មលើជនជាប់ចោទ។

-ការតម្កល់បទចោទប្រកាន់របស់តំណាងអយ្យការ តាមដីកាសន្និដ្ឋានស្ថាពរ ក្នុងពេលសវនាការដោយស្នើសុំឱ្យតុលាការផ្តន្ទាទោសទៅលើជនជាប់ចោទតាមច្បាប់ និងរក្សាទុកបទចោទប្រកាន់ទុកនៅដដែល ។ គប្បីតុលាការពិចារណាសម្រេចតាមអង្គហេតុ និងអង្គច្បាប់ ។



Scanned with CamScanner

-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ គប្បីតុលាការពិចារណាសម្រេចទៅតាមអង្គហេតុ និងអង្គច្បាប់ ។

-វត្ថុចាប់យករួមមាន៖ ម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់តូច មានទម្ងន់ ០,១៨ក្រាម, ទូរស័ព្ទម៉ាក OPPO ចំនួន ០១គ្រឿង ពណ៌ក្រហម, ម៉ូតូចំនួន ០១គ្រឿងម៉ាក គុបជ្រុង ពណ៌ទឹកប៊ិច ពាក់ស្លាកលេខ ភ្នំពេញ 1AC-1346 ។ (កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣) គប្បីសម្រេចរឹបអូស ។

-ជនជាប់ចោទបានសំណូមពរចុងក្រោយថា ខ្លួនសូមសំណូមពរដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង ព្រោះពួកខ្លួនបានដឹងពីកំហុសហើយ ។ គប្បីតុលាការពិចារណា ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ:

១.១.ឈ្មោះ [redacted]វដ្ឋា ភេទប្រុស អាយុ២៨ឆ្នាំ (ក្នុងឃុំ) (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **២ (ពីរ) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៤.០០០.០០០៛ (បួនលាន)** រៀល ។

១.២.ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៦ឆ្នាំ (ក្នុងឃុំ) (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **១ (មួយ) ឆ្នាំ** ។

ពីបទ: **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គញ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុតាងចាប់យករួមមាន៖ ម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់តូច មានទម្ងន់ ០,១៨ក្រាម, ទូរស័ព្ទម៉ាក OPPO ចំនួន ០១គ្រឿង ពណ៌ក្រហម, ម៉ូតូចំនួន ០១គ្រឿងម៉ាក គុបជ្រុង ពណ៌ទឹកប៊ិច ពាក់ស្លាកលេខ ភ្នំពេញ 1AC-1346 ។ (កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣) ត្រូវរឹបអូសតាមមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះ ជាអសាធារណៈ នៅថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០២៣ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វដ្ឋា និងចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ ។

-ភាគីដែលមិនសុខចិត្ត នឹងសេចក្តីសម្រេចនេះមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅតាកែវ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner